ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jan-2013, 11:54
CMS/CFO: Sann Rada

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
## ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៩នាទី**

**សវនាការលើកទី១៤៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន *(Mr.Dav ANSAN)*

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី *(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្ញី

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក អាកទួរ វែកកែន
*(Mr.Arthur VERCKEN)*

លោក  គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

លោកស្រី បេនី យេ *(Mrs. Beini YE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក អាកទួរ វែកគែន | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានគ្រោងទុកសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ឆោម សែ បញ្ចប់ ហើយនិងអាចត្រៀមស្តាប់សាក្សីដែលមានរហស្សនាម TCW-548។ អង្គជំនុំជម្រះក៏សូមជម្រាបជូនភាគី និងសាធារណជនជ្រាបផងដែរថាមុននឹងដំណើរការសវនាការពិភាក្សាស្តាប់សក្ខីកម្មសាក្សីនៅថ្ងៃនេះ អង្គជំនុំជម្រះជម្រាបថាលោក យូរ ឧត្តរា ចៅក្រមភាគីជាតិអវត្តមាន ដោយមានភារកិច្ចចាំបាច់ផ្ទាល់ខ្លួន ហើយគាត់មិនអាចចូលរួមកិច្ចដំណើរការសវនាការបាន។ មិនទាន់បានពិគ្រោះយោបល់នឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងភាគីជាតិជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលអវត្តមានរហូតដល់ពេលចៅក្រម យូរ ឧត្តរា មានវត្តមាន និងអាចមានលទ្ធភាពបំពេញការងារនៅក្នុងការចូលរួមកិច្ចដំណើរការសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។ សេចក្តីសម្រេចនេះ ដោយផ្អែកតាមបញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា។

[០៩:១២:០៥]

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នេះនៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែជនជាប់ចោទ នួន ជា អវត្តមានដោយមូលហេតុសុខភាព និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ ចំណែកឯជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលាសវនាការ ដោយមូលហេតុសុខភាព។ លោក ពេជ អង្គ មេធាវីនាំមុខជាតិនឹងមកយឺតនៅពេលព្រឹកនេះ ហើយសាក្សីដែលត្រូវបន្តផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក ឆោម សែ លោក

មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបម្រុងដែលផ្តល់សក្ខីកម្មបន្ទាប់ គឺសាក្សីដែលមានរហស្សនាម TCW-548។ សាក្សីរូបនេះ មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

[០៩:១៣:០៥]

សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប នួន ជា, អៀង សារី និង ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ ហើយគាត់បានធ្វើសម្បថរួចហើយនៅចំពោះមុខរូបសំណាក់លោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សាក្សីរូបនេះមិនមានមេធាវីប្រឹក្សានោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណលោកស្រី សែ កុលវុឌ្ឍី។ អម្បាញ់មិញ ឃើញមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ងើបឈរ។ សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ លោក លោកស្រីចៅក្រមជាទីគោរព!

កាលពីម្សិលមិញនេះ នៅក្នុងផ្នែកមួយនៃសវនាការពេលល្ងាច យើងបានទទួលដំណឹងថា កូនក្តីរបស់ខ្ញុំត្រូវបាននាំទៅមន្ទីរជាបន្ទាន់ ដោយហេតុថាគាត់បានដួល។ បាទ នៅក្នុងមន្ទីរឃុំខ្លួននេះឯង ដែលគាត់បានដួល។ ព្រឹកនេះយើងបានទទួលនូវរបាយការណ៍វេជ្ជសាស្ត្រដែលថា ជារបាយការណ៍បឋមរបស់វេជ្ជបណ្ឌិត ដែលចង្អុលបង្ហាញថា ដោយសារថាលក្ខខណ្ឌសុខភាពរបស់គាត់ប្រហែលជា៤ ទៅ៧ថ្ងៃដែលត្រូវសម្រាកព្យាបាល។ បាទ ដោយថាគាត់ត្រូវនៅទីនោះព្យាបាល ដោយថាយើង ថានៅថ្ងៃរសៀលថ្ងៃល្ងាចគាត់ជួបឧប្បត្តិហេតុនេះ យើងអត់មានឱកាសបានពិភាក្សាជាមួយគាត់ទេ ទាក់ទងទៅនឹងស្ថានភាពនេះ ហើយជាពិសេសទៅទៀត អំពីការពិតដែលថា ថាតើគាត់បោះបង់សិទ្ធិ ឬក៏មិនបោះបង់សិទ្ធិនោះ ក៏យើងមិនទាន់ដឹងដែរ។

[០៩:១៥:០២]

នៅពេលនេះ យើងខ្ញុំមិនអាចជម្រាបអង្គជំនុំជម្រះបានអំពីបញ្ហានេះទេ ថាតើគាត់បោះបង់សិទ្ធិ ឬមិនបោះបង់សិទ្ធិនៅក្នុងការវត្តមាននោះ? ពីព្រោះថាយើងត្រូវតែៗផ្អែកទៅលើសច្ចធារណ៍ថាគាត់មិន

បោះបង់សិទ្ធិ ពីព្រោះថារហូតទាល់តែយើងខ្ញុំមានឱកាសជួបជាមួយកូនក្ដីរបស់យើងខ្ញុំ នៅពេលដែលយើងខ្ញុំបានពិភាក្សាជាមួយគាត់ យើងខ្ញុំនឹងជម្រាបអង្គជំនុំជម្រះឲ្យបានជ្រាប ហើយយើងនឹងជម្រាបផងដែរអំពីការបោះបង់សិទ្ធិ ឬមិនបោះបង់សិទ្ធិរបស់គាត់។ ដូច្នេះ យើងស្នើសុំតុលាការថា សុំឲ្យអង្គជំនុំជម្រះផ្អាកសវនាការរហូតទាល់តែយើងខ្ញុំបានពិភាក្សា និងជូនដំណឹងមកអង្គជំនុំជម្រះវិញអំពីការបោះបង់សិទ្ធិ ឬមិនបោះបង់សិទ្ធិរបស់កូនក្ដីរបស់ខ្ញុំ នួន ជា។

[០៩:១៥:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដើម្បីឲ្យបានជាក់ច្បាស់លោកស្រី សែ កុលវុឌ្ឍី ឡើងអាននូវរបាយការណ៍របស់មន្ទីរពេទ្យមិត្តខ្មែរ-សូវៀតដែលបានទទួលពិនិត្យព្យាបាលលោក នួន ជា បន្ទាប់ពីគាត់បានទៅសម្រាកព្យាបាលនៅទីនោះចាប់ពីរសៀលកាលពីម្សិលមិញ។

**ក្រឡាបញ្ជី៖**

ក្រសួងសុខាភិបាល មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

ក្រុមគ្រូពេទ្យព្យាបាល

សូមគោរពជូនឯកឧត្ដមប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

តាមរយៈនាយកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

កម្មវត្ថុ៖ របាយការណ៍សុខភាពរបស់ជនជាប់ចោទ នួន ជា ឆ្នាំកំណើត១៩២៦ ចូលមកសម្រាកពេទ្យនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ វេលាម៉ោងដប់ប្រាំនិងប្រាំនាទី នៅផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

រោគវិនិច្ឆ័យ៖ រលាកទងសួតស្រួចស្រាល់ និងខ្សោយកម្លាំងជើងទាំងពីរ។

សេចក្ដីសន្និដ្ឋាន៖ ចាំបាច់ត្រូវសម្រាកពេទ្យពី ៤ថ្ងៃទៅ៧ថ្ងៃ ដើម្បីតាមដាន និងព្យាបាល។

តបតាមកម្មវត្ថុដូចបានជម្រាបជូនខាងលើសូមឯកឧត្ដមប្រធាន អ.វ.ត.ក មេត្តាជ្រាប។

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣

ជំនួសប្រធានផ្នែកសង្គ្រោះបន្ទាន់

វេជ្ជបណ្ឌិត គឹម សមសាន្ត

[០៩:១៧:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅភាគីពាក់ព័ន្ធដទៃទៀតមានតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាដើម តើលោកចង់មានមតិយោបល់អ្វីទេពាក់ព័ន្ធជាមួយនឹងបញ្ហាលោក នួន ជា អវត្តមាននៅពេលនេះដោយមូលហេតុគាត់ត្រូវមានជំងឺ ត្រូវទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតជាបន្ទាន់ កាលពីរសៀលម្សិលមិញនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម!

ខ្ញុំសូមអរគុណដែលលោកប្រធានបានផ្តល់ឲ្យឱកាសឲ្យយើងផ្តល់មតិ។ យើងសូម -- យើងយល់ថាដោយសំណើរបស់មេធាវីការពារក្តី នួន ជា នោះមានភាពសមស្រប ព្រោះថាពួកគាត់ត្រូវតែពិភាក្សាជាមួយនឹងកូនក្តីរបស់ពួកគាត់ ដើម្បីឲ្យដឹងថាតើកូនក្តីរបស់គាត់លះបង់សិទ្ធិ ឬក៏មិនលះបង់។ អ្វីដែលសំខាន់ចំពោះយើងនោះ គឺថាប្រសិនបើមានការលះបង់ ឬមិនលះបង់នោះ អង្គជំនុំជម្រះនិងភាគីត្រូវតែដឹងច្បាស់អំពីស្ថានភាពសុខភាពរបស់លោក នួន ជា ដើម្បីឲ្យអង្គជំនុំជម្រះអាចវាយតម្លៃបានថា តើសវនាការអាចចាប់ផ្តើមឡើងវិញនៅពេលណាបាន? ប្រសិនបើមានការលះបង់សិទ្ធិនោះ យើងគិតថាសវនាការអាចបន្តបាន។ ក៏ប៉ុន្តែគឺជាជនជាប់ចោទគាត់ជាអ្នកសម្រេចថា តើគាត់លះបង់ ឬក៏មិនលះបង់នោះ? នេះ គឺជាអ្វីដែលយើងខ្ញុំចង់លើកឡើងលោកប្រធាន សូមអរគុណ។

[០៩:១៩:២៤]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់!

ពិតណាស់នៅក្នុងដំណាក់កាលនេះ យើងយល់ស្របតាមគោលជំហររបស់សហព្រះរាជអាជ្ញា។ សំណើរបស់មេធាវីការពារក្តីមានភាពសមស្រប ដូច្នេះមេធាវីការពារក្តី នួន ជា ត្រូវអាចពិភាក្សាជាមួយគាត់ដើម្បីឲ្យដឹងថាគាត់សលះបង់សិទ្ធិ ឬក៏មិនលះបង់សិទ្ធិ។

[០៩:២០:០១]

យើងខ្ញុំសូមទទូចផងដែរថា ទោះជាយ៉ាងណាក៏ដោយយើងចង់ឲ្យសវនាការវិវត្តន៍ឈានទៅមុខ ក៏ប៉ុន្តែត្រូវតែគោរពសិទ្ធិរបស់ភាគីទាំងអស់ដែរ។ ដូច្នេះយើងចង់បានការជម្រាបអំពីការវិវត្តនៃស្ថានភាពសុខភាពរបស់លោក នួន ជា ឲ្យបានឆាប់រហ័សបំផុត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ ភាគីដទៃទៀតមាន ចង់មានមតិយោបល់អ្វីដែរឬទេ?

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់។ យើងគាំទ្រទាំងស្រុងសំណើដោយក្រុមមេធាវីការពារក្តី នួន ជា ហើយយើងបានទទួលស្គាល់កាលពីថ្ងៃមុនហើយថាយើងគោរពគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ចំពោះជនជាប់ចោទទាំងអស់ នេះជាសំណើដែលសមស្របរបស់គាត់។ បញ្ហាដែលចោទនោះគឺថា ខ្ញុំគិតថាថ្ងៃនេះ នៅពេលពួកគាត់បានជួបកូនក្តីរបស់គាត់ថាតើគាត់អាចសម្រេចចិត្តលើការបោះបង់ ឬមិនបោះបង់សិទ្ធិ គឺថាយើងនៅរង់ចាំលទ្ធផលនៃជំនួបរបស់គាត់ជាមួយមេធាវីរបស់គាត់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។

**លោក អាកទួរ វែកកែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានអ្វីបន្ថែមទេ គឺយើងខ្ញុំគាំទ្រទាំងស្រុងទៅលើសំណើរបស់មេធាវីការពារក្តីលោក នួន ជា។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

[០៩:២១:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៥:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់សម្រេចលើបញ្ហានៃការដែលផ្អាកនូវកិច្ចដំណើរការសវនាការ មិនធ្វើសវនាការ និងលទ្ធភាពនៃការចាប់ផ្តើមធ្វើ

សវនាការរបស់អង្គជំនុំជម្រះនាពេលខាងមុខ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

អង្គជំនុំជម្រះសូមកោតសរសើរចំពោះមតិយោបល់របស់មេធាវីការពារក្ដី នួន ជា ហើយនិងភាគីដទៃទៀតផងដែរ។ អង្គជំនុំជម្រះសម្រេចថា នឹងតាមដានសន្និដ្ឋានស្ថានភាពនេះជាពិសេស គឺលក្ខខណ្ឌសុខភាពរបស់លោក នួន ជា។ ហើយនិងផ្អាកសវនាការថ្ងៃនេះ នៅព្រឹកថ្ងៃពុធអង្គជំនុំជម្រះតាមរយៈលោកប្រធាននឹងជូនដំណឹងអំពីការកែប្រែនៅថ្ងៃបើកសវនាការ ហើយយើងនឹងអរគុណប្រសិនបើមេធាវីការពារក្ដីរបស់លោក នួន ជា ជូនដំណឹងមកអង្គជំនុំជម្រះឲ្យបានទាន់ពេលវេលាអំពីការពិភាក្សារបស់ខ្លួនជាមួយ នួន ជា នោះ។

[០៩:២៦:៤៣]

ហើយយើងនឹងជូនដំណឹងទៅភាគីទាំងអស់នៅក្នុងករណីដែលថាយើងនឹងចាប់ផ្ដើមនៅថ្ងៃពុធព្រឹកនោះ។ គឺជាកាលបរិច្ឆេទសម្រាប់យើងកំណត់បន្ទាប់នៅពេលដែលយើងជូន ត្រូវជូនដំណឹងទៅភាគីទាំងអស់។ តើភាគីទាំងអស់ជ្រាបច្បាស់ដែរឬទេ? ហើយខ្ញុំសង្ឃឹមថាសាធារណជនក៏នឹងជ្រាបបែបនេះដែរ ថាតើមានចម្ងល់ ឬសំណួរអ្វីដែរទេ? សូមអរគុណ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំមានសំណួរថាតើព្រឹកថ្ងៃ--

[០៩:២៧:១៦]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

យើងនឹងជូនដំណឹងទៅភាគីនៅព្រឹកថ្ងៃពុធ ប្រសិនបើយើងបើកសវនាការនៅព្រឹកថ្ងៃពុធ យើងនឹងជូនដំណឹងមុនពេលៗហ្នឹង។ ហើយយើងនឹងព្យាយាមបត់បែនទៅតាមពេលហ្នឹង។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោក លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោស្រីចៅក្រម។

បាទ ដូច្នេះអង្គជំនុំជម្រះសូមប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃពុធទី១៦ ខែមករា ឆ្នាំ២០១៣ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃពុធនេះគឺតាមកាលវិភាគដែលបានគ្រោងទុកគឺ យើងលើកសវនាការនេះទៅបន្តធ្វើនៅថ្ងៃនោះ គឺមានន័យថាយើងនឹងចាប់ផ្ដើមបន្តសួរសាក្សី សាក្សី -- សក្ខីកម្មសាក្សី ឆោម សែ បញ្ចប់ ហើយនិងត្រៀមនូវសាក្សីដែលមានរហស្សនាម TCW-548។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីទាំងពីររូបនេះវិលត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺនៅបន្ទប់រង់ចាំក្បែរនឹងបន្ទប់សវនាការនេះនៅព្រឹកថ្ងៃពុធឲ្យបានម៉ោងប្រាំបួន។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទពីររូបគឺលោក ខៀវ សំផន និងលោក អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅបន្ទប់សវនាការនេះវិញ មកកាន់នៅបន្ទប់សវនាការនេះវិញនៅវេលាថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក ដោយឡែកលោក អៀង សារី ឲ្យរក្សាទុកគាត់នៅបន្ទប់ឃុំខ្លួនខាងក្រោមដែលរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ០៩:០៩ នាទី)*